ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

-សំណុំរឿងព្រហ្មទណ្ឌលេខៈ១៨៣២
ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦
-ជំនុំជម្រះលេខៈ ៣៨៨
ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧

---------

សាលក្រមលេខៈ៤៩-ជ-
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

-បានបើកសវនាការជាសាធារណៈនៅនាទីសាលាដំបូងខេត្តសៀមរាប នៅសាលសវនាការលេខ២ ។

-កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ វេលាព្រឹក ។

-កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ វេលាព្រឹក។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោកស្រី [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា
- លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ឋានៈព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-អ្នកស្រី [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ១៨៣២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ អាសយដ្ឋានភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ [redacted] -រ- នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ -ក្នុងឃុំ-

-ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

២-ឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ អាសយដ្ឋានភូមិក្រពាំងក្រសាំង ឃុំសែនជ័យ ស្រុកវ៉ារិន ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] -ស- ម្តាយឈ្មោះ [redacted] នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ -ក្នុងឃុំ-

-ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

ត្រូវចោទពីបទ -ចាត់ចែងឲ្យប្រើប្រាស់និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុ

Scanned by CamScanner

ញៀន ប្រព្រឹត្តនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤២ កថាខណ្ឌ១,២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

លោ [redacted] ភ្នាក់ងារសង្គមកិច្ចខេត្តសៀមរាប ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ២៣៦ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ។
- បានឃើញ ដីកាដំណោះស្រាយលេខៈ ១៥២៧ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ។
- បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ៥១០ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧

**អង្គហេតុកើតមានឡើងដូចតទៅ ៖**

កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង០៨និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល សង្កាត់គោកចក បានចុះពិនិត្យល្បាតនៅត្រង់ចំណុចភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប បានប្រទះឃើញឈ្មោ [redacted] និងឈ្មោះ [redacted] ដោយមានការសង្ស័យមានពាក់ពន្ធ័នឹងការប្រើប្រាស់គ្រឿងញៀន បានធ្វើតេស្តទឹកនោមរកសារធាតុញៀនលទ្ធផលវិជ្ជមាន។ក្រោយពេលសមត្ថកិច្ចឃាត់ខ្លួនយកទៅធ្វើការសាកសួរចម្លើយរបស់ឈ្មោះ [redacted] និងឈ្មោ [redacted] បានឆ្លើយសារភាពថាធ្លាប់ប្រើប្រាស់គ្រឿងញៀនជាមួយគ្នាដោយចូលប្រាក់គ្នាទិញ ដោយថ្នាំញៀនទិញពីឈ្មោ [redacted] ភេទប្រុស អាយុប្រហែល ១៩ឆ្នាំ នៅត្រង់ចំណុចភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ។

**សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

-ជនជាប់ចោទឈ្មោ [redacted] បានធ្វើការកត់សម្គាល់ថា ៖ សុំតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សុំឲ្យតុលាការលើកលែងទោសពីបទចាត់ចែងមកជាប្រើប្រាស់គ្រឿងញៀនវិញ ។

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ចំពោះជនជាប់ចោទទាំងពីរនាក់ ពួកគាត់ពិតជាបាធ្វើសកម្មភាពទិញថ្នាំញៀនយកមកប្រើប្រាស់ជាមួយគ្នាប្រាកដមែន ឈ្មោះ [redacted] ក៏បានសារភាពថាគាត់ជាអ្នកទៅទិញយកចែកគេប្រើប្រាស់ផងដែរ ។ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋានថា ៖ ចំពោះជនជាប់ចោទឈ្មោ [redacted] គឺគាត់គ្រាន់តែយកលុយទៅទិញថ្នាំញៀនហើយយកមកប្រើប្រាស់ជាមួយឈ្មោ [redacted] ជាលក្ខណៈមិត្តភក្តិប៉ុណ្ណោះគឺគាត់មិនបានជួយអ្នកដទៃឲ្យប្រើប្រាស់នោះទេ។ តាមមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនគឺអំពើជួយអ្នកដទៃដើម្បីបញ្ចូលសារធាតុញៀនទៅក្នុងរាងកាយគឺជាអំពើចាត់ចែង ពួកគាត់គ្រាន់តែជាអ្នកទៅទិញយកមកប្រើជាមួយគ្នាគាត់មិន បានញុះញង់ឲ្យនរណាម្នាក់ឲ្យប្រើ

Scanned by CamScanner

ប្រាស់សារធាតុញៀននោះទេ។ តែចំពោះការប្រើប្រាស់វិញ គឺពួកគាត់បានសារភាពហើយៗ ពួកគាត់ក៏បានដឹងពីកំហុសហើយ ម្យ៉ាងទៀតពួកគាត់សុទ្ធតែជាអនីតិជនត្រូវការទៅរៀនសូត្របន្តទៀត ដូច្នេះសុំតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្ញុំផង ។

[redacted] ព្នាក់ងារសង្គមកិច្ចខេត្តសៀមរាប បានមានយោបល់ថា ៖ យោងតាមជនជាប់ចោទជាអនីតិជន កំពុងស្ថិតក្នុងការសិក្សា ហើយពួកគាត់ក៏បានទទួលស្គាល់នូវកំហុសរបស់ខ្លួនហើយដែរ ខ្លួនសុំបង្វែរជនជាប់ចោទទៅកាន់ទីបន្សាបគ្រឿងញៀនវិញ។

ផ្អែកតាមកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់ការសួរយកចម្លើយជនជាប់ចោទឈ្មោះ [redacted]

-ក្រោយពីបានស្តាប់ការសួរយកចម្លើយជនជាប់ចោទឈ្មោះ [redacted]

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាដំបូងខេត្តសៀមរាប</u>

<u>យល់ឃើញថា</u>

-តាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] មកធ្វើការជំនុំជម្រះពីបទ“ចាត់ចែងអោយប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន” ប្រព្រឹត្តនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២កថាខណ្ឌ១និង២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២រំលងអាធាត្រដោយសារខ្លួនបានប្រើប្រាស់គ្រឿងញៀន។ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន២០ទៅ៣០ដងរួចមកហើយ ជាមួយឈ្មោះ [redacted] ដោយខ្លួនបានពឹងឈ្មោះ [redacted] ឲ្យទិញ។ ដោយពួកបានជិះម៉ូតូទៅជាមួយគ្នាដើម្បីទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ហើយយកទៅប្រើប្រាស់នៅផ្ទះរបស់យាយខ្លួន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយនាពេលសវនាការកាលពីថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២រំលងអាធាត្រ ពេលនោះខ្លួនបានជូនសង្សារខ្លួនឈ្មោះ [redacted] ពីផ្សាររាត្រី ទៅផ្ទះនៅប៉ុស្តិ៍គោកចក ពេលដែលខ្លួនដាក់ឈ្មោះ [redacted] នៅផ្ទះហើយសមត្ថកិច្ចបានឃាត់ខ្លួនតែម្តងដោយពិនិត្យទឹកនោមឃើញមានសារធាតុវិជ្ជមាន ។ កន្លងមកខ្លួនធ្លាប់បានប្រើប្រាស់ថ្នាំញៀន២ឬ៣ដងហើយ ដោយខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ [redacted] ដើម្បីទិញថ្នាំញៀនពីឈ្មោះ [redacted] ម្តងៗចំនួន១០ដុល្លារ។

Scanned by CamScanner

-ដោយផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានឆ្លើយស៊ីសង្វាក់ដែលបានបញ្ជាក់ថាបានថាពិតជាមានករណីនៃអង្គហេតុ ចាត់ចែងអោយប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលបានបង្កឡើងដោយជនជាប់ចោទឈ្មោ[redacted]ងឈ្មោះ[redacted]ប្រាកដមែន។

-តាមអំពើរបស់ជនជាប់ចោទបានបង្ហាញពីចេតនាយ៉ាងច្បាស់ក្នុងការចាត់ចែងអោយអ្នកដទៃប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលច្បាប់តម្រូវអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២កថាខណ្ឌ១និង២នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោ[redacted]ភេទប្រុស និងឈ្មោ[redacted]ភេទប្រុស ពីបទ ចាត់ចែងអោយប្រើប្រាស់និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌ១ និង២ នៃច្បាប់ស្តីពីត្រួតពិនិត្យគ្រឿងញៀន។

-អំពើរបស់ជនជាប់ចោទបានធ្វើអោយប៉ះពាល់ដល់សុខភាពរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋជាធរមាន។

-ជនជាប់ចោទឈ្មោ[redacted] និងឈ្មោះ[redacted]សុទ្ធតែជានីតិជន ពុំមានសញ្ញាណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះទេ។

-វត្ថុតាងមានៈ១/ទូរសព្ទម៉ាកណូគា ពណ៌ខៀវ ចំនួន១គ្រឿង និងមានស៊ីមស្មាតមួយ, ២/ទូរសព្ទម៉ាកសាំស៊ុង ពណ៌ខ្មៅ ចំនួន០១គ្រឿងមានស៊ីមមិនស្គាល់, ៣/ទូរសព្ទម៉ាកសាំស៊ុង ពណ៌ស ចំនួន ០១គ្រឿង និងស៊ីមស្មាតមួយ, ៤/ ទូរសព្ទម៉ាក ណូគាពណ៌ខ្មៅ ចំនួន០១គ្រឿង និងមានស៊ីមមិនស្គាល់ វត្ថុតាងទាំងអស់ខាងលើសុទ្ធតែជាវត្ថុតាងដែលជនល្មើសប្រើសម្រាប់ទាក់ទងនិងអាស្រ័យក្នុងការប្រព្រឹត្តបទល្មើសដែលគួរតែប្បីតុលាការពិនិត្យនិងពិចារណាដោយផ្អែកតាមច្បាប់។

**ហេតុដូចនេះសម្រេច**

១/ផ្តន្ទាទោសលើឈ្មោះ[redacted]ភេទប្រុស ជាអនីតិជន ដាក់ពន្ធនាគារចំនួន០១ (មួយ) ឆ្នាំ ។

២/ផ្តន្ទាទោសលើឈ្មោ[redacted]ភេទប្រុស ជាអនីតិជន ដាក់ពន្ធនាគារចំនួន០១(មួយ) ឆ្នាំ ។

ពីបទ ចាត់ចែងអោយប្រើប្រាស់និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌ១និង២ និងមាត្រា៤៥កថាខណ្ឌ១នៃច្បាប់ស្តីពី ត្រួតពិនិត្យគ្រឿងញៀន។

៣/វត្ថុតាងមានទូរសព្ទម៉ាកណូគា ពណ៌ខៀវ ចំនួន១គ្រឿង និងមានស៊ីមស្មាតមួយ, ,ទូរសព្ទម៉ាកសាំស៊ុង ពណ៌ខ្មៅ ចំនួន០១គ្រឿងមានស៊ីមមិនស្គាល់, ទូរសព្ទម៉ាកសាំស៊ុង ពណ៌ស

Scanned by CamScanner

ចំនួន ០១គ្រឿង និងស៊ីមស្មាតមួយ, ទូរសព្ទ័ម៉ាកណូគា ពណ៌ខ្មៅ ចំនួន០១គ្រឿង និងមានស៊ីមមិនស្គាល់។ ត្រូវរឹបអូសចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ ដោយផ្អែកតាមបញ្ញត្តិមាត្រា៦២ និង៦៣ នៃក្រមព្រហ្មទណ្ឌនិង មាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤/សាលក្រមនេះជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

បើកសិទ្ធិអោយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| ហត្ថលេខា និង ត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សៀមរាប, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

[redacted]

Scanned by CamScanner